ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**
**អគ្គលេខាធិការដ្ឋាន**

លេខ:.....១០........./២០១៧អ.កបធ.សជណ

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃ**ចន្ទ ទី៣០ ខែមករា ឆ្នាំ២០១៧** វេលាម៉ោង **០៨:៣០នាទី** នៅសាលប្រជុំអគារ«ស» វិមានរដ្ឋចំការមន ក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញបានបើកសវនាការជំនុំជម្រះជាសាធារណៈលើ ៖

១- សំណុំរឿងលេខ២៦៣/០០១/២០១៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ ស្តីពីបណ្តឹងរបស់លោក **ផេង ហេង** មេធាវីតំណាងឲ្យឈ្មោះ **សឿន ធី** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៦ គ.ជ.ប ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧របស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចំនួន ៤១នាក់ នៅការិយាល័យលេខ០០១ សង្កាត់លេខ១ ខេត្តព្រះសីហនុ ចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦ ។

២- សំណុំរឿងលេខ២៦៤/០០២/២០១៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ ស្តីពីបណ្តឹងរបស់លោក **ផេង ហេង** មេធាវីតំណាងឲ្យឈ្មោះ **ភុំ អ៊ួន** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៧ គ.ជ.ប ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ របស់ គ.ជ.ប ដែលមិនលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចំនួន ៣៥ នាក់នៅការិយាល័យលេខ០០២ សង្កាត់លេខ២ ខេត្តព្រះសីហនុ ចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦ ។

ហើយបានចេញសេចក្តីសម្រេចលេខ ១៦១/០០១/២០១៧ កបធ.ច ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមសាធារណជនជ្រាប។

រាជធានីភ្នំពេញថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧